**វេទិកាពលរដ្ឋ**
**PEOPLE FORUM**

**ពលរដ្ឋខ្លាំង ជាតិខ្លាំង**
**STRONG PEOPLE STRONG NATION**

សហរដ្ឋអាមេរិក ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២២

# សេចក្តីថ្លែងការណ៍

ដោយយល់ឃើញថា **វិបត្តិនយោបាយ** វិបត្តិប្រជាធិបតេយ្យជាតិ វិបត្តិដីធ្លី ការហិនហោចនៃធនធានធម្មជាតិ វិបត្តិអយុត្តិធម៌សង្គម ឱនភាពសេដ្ឋកិច្ចពាណិជ្ជកម្ម បញ្ហាប្រេងឥន្ធនៈ/សាំងឡើងថ្លៃ កំណើនអត្រាអត់ការងារធ្វើរបស់ប្រជាពលរដ្ឋ កំណើនពលរដ្ឋចំណាកស្រុក ទំហំបំណុលជាតិជំពាក់បរទេស ភាពក្រីក្ររបស់ប្រជាពលរដ្ឋដែលក៏កំពុងប្រឈមនឹងវិបត្តិបំណុលស្ទើរគ្រប់ក្រុមគ្រួសារ និង រឿងទឹកដីព្រំដែនជាតិកម្ពុជា គឺជាបញ្ហាដែលត្រូវដោះស្រាយជាអាទិភាព …

ក្រុមអ្នកកាន់អំណាចនៅភ្នំពេញ គួរផ្តោតការយកចិត្តទុកដាក់ដោះស្រាយបញ្ហាទាំងនេះ ដើម្បីបម្រើសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ និង មិនត្រូវកែរដ្ឋធម្មនុញ្ញ ដើម្បីបំពេញសេចក្តីត្រូវការអំណាចអ្នកដឹកនាំ ធ្វើឲ្យជាតិកាន់តែស្មុគស្មាញនោះទេ។

**វេទិកាពលរដ្ឋ** សូមស្នើឲ្យលោក **ហ៊ុន សែន គណបក្សប្រជាជនកម្ពុជា រដ្ឋាភិបាលបច្ចុប្បន្ន រដ្ឋសភាឯកបក្ស** ដែលកើតពីការបោះឆ្នោតមិនយុត្តិធម៌ និង **ក្រុមប្រឹក្សាធម្មនុញ្ញ** ត្រូវបញ្ឈប់ជាបន្ទាន់ នូវគម្រោងធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ដែលមានគោលដៅ ត្រឹមតែជាការអនុវត្តផែនការផ្ទេរអំណាចឲ្យលោក **ហ៊ុន ម៉ាណែត**។

យើងខ្ញុំមើលឃើញថា **ការកែមាត្រា ១២៥ថ្មី** មានខ្លឹមសារ ***ដើម្បីគ្រាន់តែ*** បើកផ្លូវឲ្យមានការចាត់តាំងនាយករដ្ឋមន្ត្រីថ្មី និង បង្កើតរដ្ឋាភិបាលថ្មីមួយ នៅពេលណាក៏បាន តាមការចង់បានរបស់លោក **ហ៊ុន សែន**។ **ការកែមាត្រា ១១៩ថ្មី** ធ្វើឡើង ***ដើម្បីគ្រាន់តែ*** បង្កភាពងាយស្រួលចាត់តាំងលោក **ហ៊ុន ម៉ាណែត** ជានាយករដ្ឋមន្ត្រីថ្មី តាមវិធីប្រគល់អំណាចឲ្យគណបក្សនយោបាយមានអាសនៈច្រើនជាងគេក្នុងរដ្ឋសភា ជាអ្នកស្នើឲ្យ**ព្រះមហាក្សត្រ** ចាត់តាំងនាយករដ្ឋមន្ត្រីថ្មី ដែលជាការបំបាត់ចោល នូវអំណាចរដ្ឋសភា ប្រធាន និងអនុប្រធាននៃរដ្ឋសភា ពោលគឺផ្តុយពីអំណាចដឹកនាំជាតិ តាមគោលការណ៍សភានិយម។ **ការកែមាត្រា ៩៨ថ្មី** និង **មាត្រា ៨៩** ជាដើម គឺ***ដើម្បីគ្រាន់តែ*** ការពារអំណាចរដ្ឋាភិបាលថ្មីមួយ ដែលដឹកនាំដោយលោក **ហ៊ុន ម៉ាណែត** នៅពេលខាងមុខ កុំឲ្យមានអ្នកណាប៉ះពាល់បានប៉ុណ្ណោះ។

ជារួម អំពើកែរដ្ឋធម្មនុញ្ញលើកនេះ ***គឺជាការប្រមាថមើលងាយប្រជាពលរដ្ឋខ្មែរមួយនគរ*** ដែលជាម្ចាស់ប្រទេសកម្ពុជា។

**ប្រធាន វេទិកាពលរដ្ឋ**

**គឹម សុខ**

Address: 58 Poplar Street, Plains PA 18 705, USA